# ថ្នាក់បង្រៀនអង្គហេតុចម្បង
# លើកទី ១

ជំនាញការនៃគម្រោងជំនួយច្បាប់
ម៉ាអិដា យូតា

# អង្គហេតុចម្បង គឺជា

- នៅក្នុងច្បាប់ ដូចជាក្រមរដ្ឋប្បវេណីជាដើម ត្រូវបានបញ្ញត្តថា ប្រសិនបើលក្ខខណ្ឌជាក់លាក់ណាមួយត្រូវបានបំពេញ នោះសិទ្ធិជាក់លាក់ណាមួយនឹងកើតមានអានុភាព។

  ឧ. សិទ្ធិ និង ករណីយកិច្ចដោយផ្អែកតាមកិច្ចសន្យាលក់ទិញនឹងកើតឡើងតាមរយៈការព្រមព្រៀងផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ (កម្មវត្ថុ) និង ការព្រមព្រៀងបង់ថ្លៃទិញ (CC 515, 516)។

- អង្គហេតុជាក់ស្តែងដែលបំពេញលក្ខខណ្ឌដែលកំណត់ជាក់លាក់ណាមួយនោះ ហៅថា «អង្គហេតុចម្បង»។

# អង្គហេតុចម្បង គឺជា

- អង្គហេតុចម្បងមាន ៤ ប្រភេទ៖

① ការកើតឡើងសិទ្ធិ

② ឧបសគ្គនៃការកើតឡើងសិទ្ធិ

③ ការរលត់សិទ្ធិ

④ ការរាំងការអនុវត្តសិទ្ធិ

# អង្គហេតុចម្បង គឺជា

① អំពីការកើតឡើងសិទ្ធិ

- បើសិនជាអង្គហេតុជាក់លាក់ណាមួយត្រូវបានបំពេញ សិទ្ធិនឹងកើតឡើង

ឧ. ការចុះកិច្ចសន្យាលក់ទិញ

② អំពីឧបសគ្គនៃការកើតឡើងសិទ្ធិ

- បើសិនជាអង្គហេតុជាក់លាក់ណាមួយត្រូវបានបំពេញ សិទ្ធិនឹងមិនកើតមានឡើងនោះទេ។

ឧ. ការបង្ហាញឆន្ទៈមិនពិត (CC 353 កថា1)

# អង្គហេតុចម្បង គឺជា

③ អំពីការរលត់សិទ្ធិ

- បើសិនជាអង្គហេតុជាក់លាក់ណាមួយត្រូវបានបំពេញ សិទ្ធិដែលបានកើតឡើងម្តងហើយនោះនឹងរលត់វិញ។

ឧ. ការសង (CC 433 ចំណុច ក)

④ អំពីរារាំងនៃការអនុវត្តសិទ្ធិ

- បើសិនជាអង្គហេតុជាក់លាក់ណាមួយត្រូវបានបំពេញ នោះសិទ្ធិក្លាយជាមិនអាចអនុវត្តបាន។

ឧ. ការតវ៉ាឲ្យអនុវត្តព្រមគ្នា (CC 386)

# អង្គហេតុចម្បង គឺជា

- នៅក្នុងការសម្រេចសេចក្តី តុលាការនឹងវិនិច្ឆ័យអំពីភាពមាន ឬ គ្មាននៃសិទ្ធិរបស់ដើមចោទ ដោយយោងតាមការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុចម្បង។

មានន័យថា បើសិនជាតុលាការទទួលស្គាល់ នូវអង្គហេតុដែលបំពេញលក្ខខណ្ឌកើតឡើងសិទ្ធិណាមួយ នោះតុលាការនឹងត្រូវវិនិច្ឆ័យថាសិទ្ធិនោះមានអត្ថិភាព ហើយអាចអនុវត្តបាន លើកលែងតែមានការទទួលស្គាល់អង្គហេតុណាមួយដូចជា អង្គហេតុដែលជាលក្ខខណ្ឌរារាំងការកើតឡើងសិទ្ធិ ឬ រលត់សិទ្ធិ ឬ ឧបសគ្គក្នុងការអនុវត្តសិទ្ធិ។

# អង្គហេតុចម្បង គឺជា

ចំណុចពេលអតីតកាល　　　　បច្ចុប្បន្ន

① កើតឡើង

② ឧបសគ្គ

③ រលត់

④ រារាំង



# អង្គហេតុចម្បង គឺជា

- ការទទួលខុសត្រូវក្នុងការអះអាង

  បើភាគីមិនអះអាងអំពីអង្គហេតុចម្បងមួយចំនួនចំពោះតុលាការទេ ជាលទ្ធផល ភាគីនោះនឹងបាត់បង់ផលប្រយោជន៍ ពីការដែលតុលាការមិនទទួលស្គាល់ការកើតឡើងនូវអានុភាពគតិយុត្តិ ។

  នៅក្នុងការសម្រេចសេចក្តី អង្គហេតុដែលមិនបានអះអាងដោយភាគី តុលាការមិនអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងបានឡើយ (CCP 95)។

- ការទទួលខុសត្រូវក្នុងការបញ្ជាក់

  នៅពេលដែលអង្គហេតុចម្បងមួយចំនួនត្រូវបានសម្រេចថាមានភាពមិនច្បាស់លាស់ ភាគីនឹងបាត់បង់ផលប្រយោជន៍ដែលតុលាការមិនទទួលស្គាល់ការកើតឡើងនូវអានុភាពគតិយុត្តិ។

# អង្គហេតុចម្បង គឺជា

- ការទទួលខុសត្រូវក្នុងការអះអាង និង បញ្ជាក់

អង្គហេតុចម្បងបែងចែកជា ① អង្គហេតុកើតឡើងសិទ្ធិ ② អង្គហេតុរារាំងការកើតឡើងសិទ្ធិ ③ អង្គហេតុរលត់សិទ្ធិ និង ④ អង្គហេតុជាឧបសគ្គនៃការអនុវត្តសិទ្ធិ ហើយភាគីដែលទទួលបានផលប្រយោជន៍ ពីការកើតឡើងអនុភាពគតិយុត្តិអំពីអង្គហេតុនីមួយៗ មានទំនួលខុសត្រូវក្នុងការអះអាង និង បញ្ជាក់។

ឧ. នៅក្នុងការទាមទារឲ្យប្រគល់ប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ដើមចោទទទួលខុសត្រូវអះអាង និង បញ្ជាក់អំពីការចុះកិច្ចសន្យាលក់ទិញ (លក្ខខណ្ឌបង្កើតសិទ្ធិ) ចំណែកឯ ចុងចម្លើយទទួលខុសត្រូវក្នុងការអះអាង និង បញ្ជាក់អំពីការសងប្រាក់ថ្លៃទិញ (លក្ខខណ្ឌរលត់សិទ្ធិ) រៀងៗខ្លួន។

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

តើអង្គហេតុចម្បងនៃការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញជាអ្វី?



X បានលើកឡើង

នៅថ្ងៃទី៣ ខែ មិនា ឆ្នាំ២០១៧ ខ្ញុំបានលក់ត្បូង ២ ដែលបន្សល់ទុកតាំងពីដូនតាមក ទៅឲ្យ Y ដែលតែងនិយាយថាចង់បានត្បូងនោះ និង បានប្រគល់ត្បូង ២ ឲ្យគាត់រួចរាល់។ យើងបានសន្យាគ្នាថា ថ្លៃទិញគឺ ១0000$ ហើយថ្ងៃបង់ប្រាក់គឺ ថ្ងៃទី៣ ខែមេសា ឆ្នាំដដែល។ ក្រោយមក Y តែងនិយាយត្អូញត្អែ និង មិនបានបង់ប្រាក់ថ្លៃទិញមកឲ្យខ្ញុំទេ។ ហេតុនេះ ខ្ញុំទាមទារឲ្យគាត់បង់ប្រាក់ថ្លៃទិញ ១0000$ មក។

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

- គោលបំណងនៃការទាមទារ (សាលក្រមដែលដើមចោទទាមទារ)
  បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ ១០០០០$ ឲ្យទៅដើមចោទ។

- កម្មវត្ថុនៃបណ្តឹង (សិទ្ធិ និង ទំនាក់ទំនងគតិយុត្តដែលដើមចោទចង់ឲ្យសម្រេចក្នុងសាលក្រម)
  សិទ្ធិទាមទារឲ្យប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ចំនួន ១

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

- CC 515

ការលក់ទិញសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឲ្យទៅភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញជាប្រាក់ឲ្យអ្នកលក់។

- CC 516

កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែ ភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬ លិខិតឯកជន ជាលក្ខខណ្ឌសម្រាប់បង្កើតកិច្ចសន្យាបាន។

⇒អង្គហេតុចម្បងនៃកិច្ចសន្យាលក់ទិញ គឺ

<u>ការព្រមព្រៀងផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ (កម្មវត្ថុ) និង ការព្រមព្រៀងបង់ប្រាក់ថ្លៃទិញ</u>

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

• តើ X ត្រូវអះអាងអង្គហេតុបែបណាខ្លះ?

①កម្មវត្ថុ និង ថ្លៃលក់ទិញ

ដើម្បីអះអាងអំពីអង្គហេតុចម្បងនៃកិច្ចសន្យាលក់ទិញដែលជាការព្រមព្រៀងផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ (កម្មវត្ថុ) និង ការព្រមព្រៀងបង់ប្រាក់ថ្លៃលក់ទិញបាន លុះត្រាតែកម្មវត្ថុ និង ថ្លៃលក់ទិញនោះបានសម្រេចរួចរាល់។

⇒ចាំបាច់ត្រូវអះអាង

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

- តើ X ត្រូវអះអាងអង្គហេតុបែបណាខ្លះ?

②ពេលកំណត់អនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្លៃលក់ទិញ

បើសិនជាកិច្ចសន្យាលក់ទិញបានបង្កើត ជាគោលការណ៍ អ្នកលក់ដែលជា X អាចទាមទារឲ្យបង់ប្រាក់ថ្លៃទិញពីអ្នកទិញបានភ្លាមៗ។

⇒មិនចាំបាច់អះអាង

※ការព្រមព្រៀងអំពីពេលកំណត់អនុវត្តគឺជា លក្ខខណ្ឌរារាំងនៃការអនុវត្តសិទ្ធិទាមទារឲ្យបង់ប្រាក់ថ្លៃទិញ ហេតុនេះ ចុងចម្លើយត្រូវអះអាងអំពីចំណុចនេះ។

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

- តើ X ត្រូវអះអាងអង្គហេតុបែបណាខ្លះ?

③ការដែលអ្នកលក់ត្រូវមានកម្មសិទ្ធិលើកម្មវត្ថុ

នៅក្នុងក្រមរដ្ឋប្បវេណី ការដែលអ្នកលក់ត្រូវមានកម្មសិទ្ធិលើកម្មវត្ថុ មិនមែនជាលក្ខខណ្ឌនៃកិច្ចសន្យាលក់ទិញនោះទេ ហើយកិច្ចសន្យាលក់ទិញវត្ថុរបស់អ្នកដទៃក៏មានអានុភាពដែរ (CC 531 កថា2)

⇒មិនចាំបាច់អះអាង

④ការប្រគល់កម្មវត្ថុ

កិច្ចសន្យាលក់ទិញកើតឡើងដោយការព្រមព្រៀងប៉ុណ្ណោះ (CC 516) ហេតុនេះ ការប្រគល់កម្មវត្ថុមិនមែនជាលក្ខខណ្ឌនៃកិច្ចសន្យាលក់ទិញនោះទេ

⇒មិនចាំបាច់អះអាង

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

- តើ X ត្រូវអះអាងអង្គហេតុបែបណាខ្លះ?

⑤មិនបង់ប្រាក់ថ្លៃទិញ

បើសិនជាកិច្ចសន្យាលក់ទិញបានបង្កើត ជាគោលការណ៍ អ្នកលក់ដែលជា X អាចទាមទារឲ្យបង់ប្រាក់ថ្លៃទិញពីអ្នកទិញបានភ្លាមៗ។

⇒ មិនចាំបាច់អះអាង

※ការបង់ថ្លៃទិញគឺជាលក្ខខណ្ឌរលត់សិទ្ធិទាមទារប្រាក់ (ការសង) ហេតុនេះចុងចម្លើយត្រូវអះអាងអំពីចំណុចនេះ។

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញ

- តើ X ត្រូវអះអាងអង្គហេតុបែបណាខ្លះ?

⑥ថ្ងៃធ្វើកិច្ចសន្យា និង ភាគីនៃកិច្ចសន្យា

សិទ្ធិទាមឲ្យអនុវត្តដោយផ្អែកលើកិច្ចសន្យាត្រូវបានកំណត់ដោយសារប្រធាននៃសិទ្ធិទាមទារ និង ភាគីម្ខាងទៀត ព្រមទាំងខ្លឹមសារនៃសិទ្ធិ។

ជាទូទៅ ក្នុងករណីសិទ្ធិទាមទារឲ្យបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញត្រូវបានកំណត់ដោយ ភាគីនៃកិច្ចសន្យា ថ្ងៃចុះកិច្ចសន្យា កម្មវត្ថុ និង ថ្លៃលក់ទិញជាដើម។

⇒ចាំបាច់ត្រូវអះអាង

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់វិញ

- មូលហេតុនៃការទាមទារ គឺជា

  អង្គហេតុចម្បងដែលចាំបាច់ដើម្បីបង្កើតសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង

- មូលហេតុនៃការទាមទារក្នុងករណីនេះ

  នៅថ្ងៃទី៣ ខែ មិនា ឆ្នាំ ២០១៧ ដើមចោទបានលក់ត្បូង ៤ ក្នុងតម្លៃ ១0000$ ឲ្យទៅ ចុងចម្លើយ។

# ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

①ទទួលស្គាល់(ការសារភាព)

②នៅស្ងៀម

　ត្រូវចាត់ទុកថាបានសារភាព លើកលែងតែករណីតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ (CCP 96 កថា 1)

③មិនដឹង

　ត្រូវសន្មតថាបានតវ៉ាអំពីអង្គហេតុ (CCP 96 កថា 2)

④បដិសេធ

# ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

## ការបដិសេធ និង ការតវ៉ា



ចំពោះការទិញលក់ត្បូង ២ ទាំង X និង ខ្ញុំមិនមានបញ្ហាអ្វីនោះទេ ប៉ុន្តែ នៅចុងក្រោយ ពួកយើងមិនអាចឈានដល់ការព្រមព្រៀងគ្នារឿងតម្លៃបានទេ។ ហើយខ្ញុំឮថា X មិនបានទទួលត្បូង ២ នោះពីដូនតាអ្វីនោះទេ គឺគាត់បានទទួលប្រទានកម្មពីលោកតា A ប៉ុណ្ណោះ។

Y បានលើកឡើង

# ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

ការបដិសេធ និង ការតវ៉ា

- ការតវ៉ា･･･ជាអង្គហេតុដែលកើតឡើងស្របគ្នានឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយអានុភាពគតិយុត្តិនៃការអះអាងនោះរារាំង (ឧបសគ្គ រំលត់ ឬ រារាំង) នូវការកើតឡើងអានុភាពគតិយុត្តិដែលកើតចេញពីមូលហេតុនៃការទាមទារ។

※អង្គហេតុដែលមិនស្របគ្នានឹងមូលហេតុនៃការទាមទារគឺជា ការបដិសេធ មិនមែនជាការតវ៉ាទេ

# ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

ការបដិសេធ និង ការតវ៉ា

- X អះអាងថាមានការព្រមព្រៀងគ្នាអំពីថ្លៃលក់ទិញចំនួន ១0000$ ធ្វើជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ ប៉ុន្តែ Y អះអាងថាមិនមានការព្រមព្រៀងគ្នាអំពីថ្លៃលក់ទិញនោះទេ។

⇒អង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ការអះអាងរបស់ Y មិនស្របគ្នានោះទេ ហេតុនេះ ការអះអាងរបស់ Y គឺជាការបដិសេធចំពោះមូលហេតុនៃការទាមទារ។

# ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

ការបដិសេធ និង ការតវ៉ា

- ការឆ្លើយតបចំពោះអង្គហេតុដែលមិនមែនជាមូលហេតុនៃការទាមទារ (X មិនបានទទួលត្បូង ២ នោះពីដូនតាអ្វីនោះទេ គឺគាត់បានទទួលប្រទានកម្មប៉ុណ្ណោះ។) ហើយក៏មិនមែនជា ការបដិសេធ ឬ ការតវ៉ានោះទេ។
- Y មិនបានអះអាងអង្គហេតុដែលត្រូវនឹងការតវ៉ានោះទេ។

# សន្និដ្ឋាន

- មូលហេតុនៃការទាមទារ

  នៅថ្ងៃទី៣ ខែ មិនា ឆ្នាំ ២០១៧ ដើមចោទ បានលក់ត្បូង ៤ ក្នុងតម្លៃ ១0000$ ឲ្យទៅ ចុងចម្លើយ។

- ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

  ចុងចម្លើយបដិសេធអំពីមូលហេតុនៃការទាមទារ។

| |
|---|
| អង្គហេតុចម្បងនៃកិច្ចសន្យាលក់ទិញ គឺ ① ការព្រមព្រៀងផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ (កម្មវត្ថុ) និង ② ការព្រមព្រៀងបង់ប្រាក់ថ្លៃលក់ទិញ |

# អរគុណ

# ការបង្រៀនអំពីអង្គហេតុចម្បង
# លើកទី២

ជំនាញការនៃគម្រោងជំនួយច្បាប់
ម៉ាអិដា យូតា

# ការបដិសេធ និង ការតវ៉ា

• ការតវ៉ាគឺជា

អង្គហេតុដែលស្របគ្នានឹងមូលហេតុនៃការទាមទារ ដោយទទួលស្គាល់មូលហេតុនៃការទាមទារដែលដើមចោទបានអះអាងជាមុន (ត្រូវបានទទួលស្គាល់ដោយផ្អែកលើការសារភាព ឬ ភស្តុតាង) ហើយជាអង្គហេតុត្រូវនឹងលក្ខខណ្ឌគតិយុត្តដែលនាំឲ្យការកកើតឡើងនៃសិទ្ធិដែលនាំឲ្យមានអត្ថិភាពនៃការទាមទារ (អានុភាពគតិយុត្ត) ជួបឧបគ្គសគ្គ, ធ្វើឲ្យសិទ្ធិនោះរលត់, ឬ រារាំងការអនុវត្តសិទ្ធិនោះ។

ឧ) ការបង្ហាញឆន្ទៈមិនពិត (ក្រមរដ្ឋប្បវេណី មាត្រា ៣៥៣ កថា.1) (ការតវ៉ាអំពីឧបសគ្គ)
ការសង (ក្រមរដ្ឋប្បវេណី មាត្រា៤៣៣ ចំណុច ក) (ការតវ៉ាអំពីការរលត់)
ការតវ៉ាអំពីការអនុវត្តព្រមគ្នា (ក្រមរដ្ឋប្បវេណី មាត្រា ៣៦៦) (ការតវ៉ាអំពីការរារាំង)

# ការបដិសេធ និង ការតវ៉ា

- ទោះបីជាយើងបានបដិសេធមូលហេតុនៃការទាមទារក៏ដោយ ក៏យើងអាចអះអាងការតវ៉ាដើម្បីត្រៀមជាមុន ក្នុងករណីតុលាការទទួលស្គាល់មូលហេតុនេះការទាមទារ។
- ក្នុងករណីនេះ តុលាការត្រូវសម្រេចតាមលំដាប់ ①អាចទទួលស្គាល់មូលហេតុនៃការទាមទារដែរ ឬទេ? →②អាចទទួលស្គាល់ការតវ៉ាដែរ ឬទេ? ប្រសិនបើមិនអាចទទួលស្គាល់មូលហេតុនៃការទាមទារទេ តុលាការនឹងត្រូវច្រានចោលការទាមទារ ដោយមិនចាំបាច់សម្រេចអំពីការតវ៉ាទេ។

# ការបដិសេធ និង ការតវ៉ា

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៧ ខ្ញុំបានលក់គ្រឿងអលង្ការ J ឲ្យទៅ Y ក្នុងតម្លៃចំនួន១ម៉ឺនដុល្លារ ហើយក៏បានប្រគល់គ្រឿងអលង្ការ J នៅថ្ងៃនោះដែរ។ ខ្ញុំទាមទារឲ្យ Y បង់ប្រាក់ថ្លៃលក់។



ផ្នែកដែលXនិយាយ

①យើងមិនទាន់មានការព្រមព្រៀងអំពីតម្លៃនៅឡើយទេ។
②នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ខ្ញុំបានបង់ថ្លៃលក់ចំនួន១ម៉ឺនដុល្លារឲ្យទៅ X។



ផ្នែកដែលYនិយាយ

# ការបដិសេធ និង ការតវ៉ា

- ការអះអាងរបស់ Y ① "មិនទាន់មានការព្រមព្រៀងអំពីតម្លៃនៅឡើយទេ"

→ផ្ទុយទៅនឹងការបង្កើតកិច្ចសន្យាលក់ទិញដែលត្រូវជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ (ការព្រមព្រៀងអំពីការប្រគល់កម្មវត្ថុ + ការព្រមព្រៀងអំពីចំនួនប្រាក់)

⇒បដិសេធ

- ការអះអាងរបស់ Y ② "បានបង់ថ្លៃលក់"

→ស្របទៅនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ប៉ុន្តែ ប្រសិនបើការសងត្រូវបានទទួលស្គាល់ នោះសិទ្ធិទាមទារឲ្យបង់ថ្លៃលក់របស់ X នឹងរលត់

⇒ការតវ៉ា

# ការបដិសេធ និង ការតវ៉ា



# ការមិនទទួលស្គាល់ និង ការតវ៉ា

- ការសម្រេចរបស់តុលាការ



# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់វិញ



នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១២ ខ្ញុំបានលក់គ្រឿងអលង្ការដែលជាកម្មសិទ្ធិរបស់ខ្ញុំបានទទួលបន្តពីដូនតាជំនាន់មុនៗ ឲ្យទៅ Y ដែលបាននិយាយមកកាន់ខ្ញុំថា ចង់បានគ្រឿងអលង្ការនោះខ្លាំងណាស់។ នៅថ្ងៃនោះ ខ្ញុំបានធ្វើកិច្ចសន្យាលក់ទិញក្នុងតម្លៃប្រាក់១ម៉ឺនដុល្លារ ហើយបានប្រគល់គ្រឿងអលង្ការនៅថ្ងៃនោះផងដែរ។ ប៉ុន្តែ Y បាននិយាយត្អូញត្អែរជាច្រើន ហើយមិនបានបង់ប្រាក់នោះមកឲ្យខ្ញុំឡើយ។ ដូច្នេះ ហើយទើបខ្ញុំទាមទារឲ្យបង់ប្រាក់ចំនួន១ម៉ឺនដុល្លារ។

ផ្នែកដែលX
បាននិយាយ

# ការទាមទារឲ្យបង់ប្រាក់ថ្លៃលក់វិញ

- គោលគំនិតនៃការទាមទារ

  បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់មកឲ្យដើមចោទចំនួន១ម៉ឺនដុល្លារ។

- កម្មវត្ថុនៃបណ្ដឹង

  សិទ្ធិទាមទារឲ្យបង់ប្រាក់ដោយផ្អែកតាមកិច្ចសន្យាលក់ទិញ  ចំនួន1

- មូលហេតុនៃការទាមទារ

  នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១២ ដើមចោទបានលក់គ្រឿងអលង្ការក្នុងតម្លៃ១ម៉ឺនដុល្លារឲ្យទៅចុងចម្លើយ។

# ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល



ផ្នែកដែល Y បាននិយាយ

ខ្ញុំមិនបាននិយាយថា ចង់បានគ្រឿងអលង្ការៗនោះទេ វាជារបស់ដែល X បានលក់ ដោយសារតែបានជួបបញ្ហាក្នុងការបង់ពន្ធ។ ចំពោះខ្ញុំដោយសារតែអារម្មណ៍ចង់ជួយគេ ក៏បានគិតថាតើគួរទិញវាដែរឬទេ ? ប៉ុន្តែ ចុងក្រោយ មិនបានឈានដល់ការបង្កើតកិច្ចសន្យាលក់ទិញនោះទេ។ ទោះបីជាគិតថា កិច្ចសន្យាលក់ទិញបានបង្កើតឡើងក៏ដោយ ក៏ករណីយកិច្ចបង់ប្រាក់ចំនួន១ម៉ឺនដុល្លារនោះបានរលត់ដោយអាជ្ញាយុកាលដែរ។

# ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

- ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ
  បដិសេធ

- ការអះអាងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល
  ស្របទៅនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយក្លាយទៅជាមូលហេតុនៃការរំលត់នូវសិទ្ធិលើបំណុលចំពោះថ្លៃលក់ទិញ

  ⇒ការតវ៉ា

# ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

- អង្គហេតុចម្បងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

①នៅពេលដែលអាចអនុវត្តសិទ្ធិបាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨១ )

②៥ឆ្នាំបានកន្លងផុតគិតចាប់ពី① (ក្រមរដ្ឋប្បវេណី មាត្រា ៤៨២ )

③អ្នកដែលមានសិទ្ធិលើកឡើង បានបង្ហាញឆន្ទៈលើកឡើងអំពីអាជ្ញាយុកាលចំពោះភាគីម្ខាងទៀត (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៦ កថាខណ្ឌទី១)

# ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

- អង្គហេតុចម្បងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

①នៅពេលដែលអាចអនុវត្តសិទ្ធិបាន (ក្រមរដ្ឋប្បវេណី មាត្រា ៤៨១ )

※តាមរយៈការអះអាងរបស់ដើមចោទអំពីការបង្កើតកិច្ចសន្យាដែលជាមូលហេតុនៃការទាមទារ　គឺជាការបង្ហាញអំពីស្ថានភាពដែលអាចអនុវត្តសិទ្ធិលើបំណុលនៃថ្លៃលក់ទិញចាប់ពីពេលដែលបានចុះកិច្ចសន្យាលក់ទិញ។

→ដោយសារតែការតវ៉ាជាការទទួលស្គាល់ជាមុននូវមូលហេតុនៃការទាមទារ ដូច្នេះមិនចាំបាច់អះអាងជាថ្មីនូវអង្គហេតុដែលបង្ហាញដោយមូលហេតុនៃការទាមទារនោះទេ។

⇒អង្គហេតុដែលត្រូវតែអះអាងគឺ ② និង ③

# ការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

- ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះការតវ៉ា

②៥ឆ្នាំបានកន្លងផុតគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិបាន

＝ថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៧បានកន្លងផុត

⇒ អង្គហេតុដែលមានភាពជាក់ស្តែង (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ១២៣ កថា.ទី២ )

ដូច្នេះ មិនចាំបាច់ធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ឡើយ។

③ អ្នកដែលមានសិទ្ធិលើកឡើង បានបង្ហាញឆន្ទៈលើកឡើងអំពីអាជ្ញាយុកាលចំពោះភាគីម្ខាងទៀត

ឧ) ចុងចម្លើយបានបង្ហាញឆន្ទៈលើកឡើងអំពីអាជ្ញាយុកាលទៅកាន់ដើមចោទ នៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧។

⇒ ប្រសិនបើត្រូវបានធ្វើឡើងនៅក្នុងនីតិវិធីនៃបណ្តឹង គឺជាអង្គហេតុដែលមានភាពជាក់ស្តែងចំពោះតុលាការ។

# សរុប

- មូលហេតុនៃការទាមទារ

  នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១២ ដើមចោទបានលក់គ្រឿងអលង្ការក្នុងតម្លៃ១ម៉ឺនដុល្លារឲ្យទៅចុងចម្លើយ។
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

  មិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ។
- ការតវ៉ា (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល)

(1) ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៧ បានកន្លងផុត ។

(2) នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ ចុងចម្លើយបានលើកឡើងអំពីអាជ្ញាយុកាលខាងលើទៅកាន់ដើមចោទ។

# សរុប

…បើទោះបីជាមូលហេតុនៃការទាមទារត្រូវបានទទួលស្គាល់ក៏ដោយ អង្គហេតុចម្បងនៃការតវ៉ា គឺជាអង្គហេតុដែលមានភាពជាក់ស្តែងទាំងអស់ ហើយជាលទ្ធផល ការតវ៉ានឹងត្រូវបានទទួលស្គាល់ ដូច្នេះ ការទាមទាររបស់ដើមចោទ ត្រូវបានច្រានចោល។ តើដើមចោទគួរធ្វើបែបណា?

# Appendix )ការតវ៉ាតប

- ការតវ៉ាតបគឺជា

អង្គហេតុដែលស្របគ្នានឹងមូលហេតុនៃការទាមទារ និង ការតវ៉ាចំពោះមូលហេតុនៃការទាមទារដោយទទួលស្គាល់មូលហេតុនៃការទាមទារដែលដើមចោទបានអះអាង និង ការតវ៉ាជាក់លាក់ណាមួយដែលចុងចម្លើយបានអះអាងជាមុន (ត្រូវបានទទួលស្គាល់ដោយផ្អែកលើការសារភាព ឬ ភស្តុតាង) ហើយជាអង្គហេតុត្រូវនឹងលក្ខខណ្ឌគតិយុត្តដែលនាំឲ្យការកកើតឡើងនៃអានុភាពគតិយុត្តដោយផ្អែកលើការតវ៉ានោះជួបឧបគ្គសគ្គ, ធ្វើឲ្យសិទ្ធិរលត់, ឬ រារាំងការអនុវត្តសិទ្ធិ។

ឧ) ការទាមទារតាមផ្លូវតុលាការចំពោះការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុល (ក្រមរដ្ឋប្បវេណីមាត្រា ៤៨៩ ចំណុច ក.)

# Appendix )ការតវ៉ាតប

- ការតវ៉ាតប ត្រូវបានអះអាងចំពោះការតវ៉ាជាក់លាក់ណាមួយ។

ឧ)



# ចប់

# ការបង្រៀនអំពីអង្គហេតុចម្បង លើកទី៣

ជំនាញការនៃគម្រោងជំនួយច្បាប់
ម៉ាអិដា យូតា

# កំណត់ពេល ឬ លក្ខខណ្ឌ

• កំណត់ពេល-លក្ខខណ្ឌ គឺជា

ការព្រមព្រៀងអំពីអង្គហេតុដែលបានកំណត់ជាក់លាក់នៅពេលអនាគត ដែលធ្វើឲ្យការកើតឡើង ឬ ការរលត់នូវអានុភាពរបស់សកម្មភាពគតិយុត្ត ឬ ការអនុវត្តកាតព្វកិច្ចដែលកើតចេញពីសកម្មភាពគតិយុត្ត។

ក្នុងករណីដែលអង្គហេតុនោះមិនទៀងទាត់ថា អាចសម្រេចបាន ឬ មិនបាន គេហៅថា "លក្ខខណ្ឌ" ហើយក្នុងករណីដែលទៀងទាតថាអាចសម្រេចបាន គេហៅថា " កំណត់ពេល"។

ឧ) ប្រសិនបើប្រលងចូលសាកលវិទ្យាល័យជាប់ ខ្ញុំនឹងឲ្យប្រាក់ចំនួន100$ (លក្ខខណ្ឌ)

ចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2018 តទៅ ខ្ញុំនឹងឲ្យជួលបន្ទប់(កំណត់ពេល)

# កំណត់ពេល ឬ លក្ខខណ្ឌ

• តើកំណត់ពេល ឬ លក្ខខណ្ឌ គឺជាលក្ខ័ខណ្ឌ័នៃការបង្កើតសកម្មភាពគតិយុត្ត ឬទេ?

⇒NO

ឧ) លក្ខ័ខណ្ឌ័នៃការបង្កើតកិច្ចសន្យាលក់ទិញ គឺមាន ការព្រមព្រៀងផ្ទេរនូវសិទ្ធិលើទ្រព្យសម្បត្តិ (កម្មវត្ថុនៃកិច្ចសន្យា) និង ការព្រមព្រៀងបង់ប្រាក់តែប៉ុណ្ណោះ (ក្រមរដ្ឋប្បវេណី មាត្រា515 និង មាត្រា516) ហើយការព្រមព្រៀងអំពីកំណត់ពេលអនុវត្តករណីយកិច្ចបង់ប្រាក់ ពុំមែនជាលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យានេះទេ។

# កំណត់ពេល ឬ លក្ខខណ្ឌ

- តាមរយៈការភ្ជាប់នូវកំណត់ពេល ឬ លក្ខខណ្ឌនេះ វាធ្វើឲ្យសុពលភាពគតិយុត្តមិនទាន់កើតមានឡើង ឬ សុពលភាពគតិយុត្តដែលបានកើតមានឡើងម្តងហើយរលត់ទៅវិញ ឬ មិនអាចអនុវត្តសិទ្ធិដែលកំពុងតែកើតមានឡើងជាដើម។

⇒កំណត់ពេល ឬ លក្ខខណ្ឌនឹងក្លាយទៅជាការតវ៉ា។

# ការទាមទារប្រាក់ថ្លៃលក់វិញ



នៅថ្ងៃទី4 ខែតុលា ឆ្នាំ2017 ខ្ញុំបានលក់កុំព្យូទ័រLaptop C ក្នុងតម្លៃ 2000$ ហើយបានប្រគល់ឲ្យទៅ Y ដោយសន្យាចំពោះកាលបរិច្ឆេទបង់ប្រាក់នៅថ្ងៃទី13 ខែតុលា ។ ដូច្នេះ ខ្ញុំទាមទារឲ្យ Y បង់ប្រាក់ចំនួន 2000$។

ការអះអាងរបស់ X



មិនខុសទេ ខ្ញុំពិតជាបានទិញកុំព្យូទ័រ Laptop C ពី X មែន ប៉ុន្តែ ខ្ញុំបានសន្យាថាបង់ប្រាក់នៅថ្ងៃទី29 ខែធ្នូ ឆ្នាំ2017 ឯណោះវិញទេ ដូច្នេះ ថ្ងៃនោះ មិនទាន់បានមកដល់នៅឡើយ។

ការអះអាងរបស់ Y

# ការទាមទារប្រាក់ថ្លៃលក់ទិញ

- គោលបំណងនៃការទាមទារ

  បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន 2000$ មកឲ្យដើមចោទ។

- កម្មវត្ថុនៃបណ្តឹង

  សិទ្ធិទាមទារឲ្យបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ចំនួន1

- មូលហេតុនៃការទាមទារ

  នៅថ្ងៃទី4 ខែតុលា ឆ្នាំ2017 ដើមចោទបានលក់កុំព្យូទ័រ Laptop C ឲ្យទៅចុងចម្លើយក្នុងតម្លៃ 2000$។

# ការទាមទារប្រាក់ថ្លៃលក់ទិញ

- ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

  ទទួលស្គាល់មូលហេតុនៃការទាមទារ។

- ការតវ៉ា (កំណត់ពេលនៃការអនុវត្ត)

  នៅពេលធ្វើកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយ បានព្រមព្រៀងគ្នាថា យកថ្ងៃទី29 ខែធ្នូ ឆ្នាំ2017 ជាកាលបរិច្ឆេទបង់ប្រាក់។

- ការទទួលស្គាល់ ឬ បដិសេធចំពោះការតវ៉ា

  បដិសេធការតវ៉ា។

# ការទាមទារប្រាក់ថ្លៃលក់វិញ

• តើការអះអាងអំពីការមិនទាន់មកដល់នៃការកំណត់ពេល មានភាពចាំបាច់ដែរឬទេ?

ប្រសិនបើកិច្ចសន្យាមានភ្ជាប់កំណត់ពេលសម្រាប់អនុវត្តសិទ្ធិលើបំណុលចំពោះប្រាក់ នោះយើងគ្មានភាពចាំបាច់ក្នុងការបង់ប្រាក់នោះទេ រហូតដល់ការកំណត់ពេលនោះបានមកដល់។ អង្គហេតុអំពី "ការកំណត់ពេលបានមកដល់" គឺស្របគ្នានឹងអង្គហេតុនៃការអះអាងអំពីការកំណត់ពេល ហើយវាធ្វើឲ្យអានុភាពនៃការអះអាងអំពីកំណត់ពេលនឹងត្រូវបាត់បង់។

⇒ចំពោះការតវ៉ាអំពីកំណត់ពេលអនុវត្ត យើងមិនចាំបាច់អះអាងអំពីការមិនទាន់មកដល់នៃកំណត់ពេលនោះទេ ហើយការមកដល់នៃកំណត់ពេល នឹងក្លាយទៅជាការតវ៉ាតបចំពោះការតវ៉ាអំពីកំណត់ពេលអនុវត្ត។

# សរុប

- មូលហេតុនៃការទាមទារ

  នៅថ្ងៃទី4 ខែតុលា ឆ្នាំ2017 ដើមចោទបានលក់កុំព្យូទ័រ Laptop C ឲ្យទៅចុងចម្លើយក្នុងតម្លៃ 2000$។
- ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

  ទទួលស្គាល់មូលហេតុនៃការទាមទារ។
- ការតវ៉ា (កំណត់ពេលនៃការអនុវត្ត)

  នៅពេលធ្វើកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ ដើមចោទ និង ចុងចម្លើយ បានព្រមព្រៀងគ្នាថា យកថ្ងៃទី 29 ខែធ្នូ ឆ្នាំ 2017 ជាកាលបរិច្ឆេទបង់ប្រាក់។
- ការទទួលស្គាល់ ឬ បដិសេធចំពោះការតវ៉ា

  បដិសេធការតវ៉ា ។

# ចប់

# ការបង្រៀនអំពីអង្គហេតុចម្បង
# លើកទី៤

ជំនាញការនៃគម្រោងជំនួយច្បាប់
ម៉ាអិដា យូតា

# ការទាមទារឲ្យសងប្រាក់កម្ចី

នៅថ្ងៃទី8 ខែសីហា ឆ្នាំ2016 កូនប្រសារឈ្មោះ Y (ប្រពន្ធរបស់កូនប្រុស A) បានមកសុំអង្វរខ្ចីប្រាក់ចំនួន 10ម៉ឺនដុល្លារ ឲ្យបាន ដើម្បីយកមកធ្វើជាដើមទុនសម្រាប់បើកក្រុមហ៊ុន ដូច្នេះ នៅថ្ងៃដដែលនោះ ខ្ញុំ និង Y បានព្រមព្រៀងគ្នាថា ខ្ញុំឲ្យខ្ចីប្រាក់ចំនួន 10ម៉ឺនដុល្លារ ដោយសន្យាយកការប្រាក់ 10%ក្នុងមួយឆ្នាំ និងយកថ្ងៃទី 1 ខែធ្នូ ឆ្នាំ2016 ជាកាលបរិច្ឆេទនៃការសង ហើយនៅថ្ងៃដែលបានព្រមព្រៀងគ្នានោះ ខ្ញុំបានទៅធនាគារ B ហើយបានប្រគល់ជាសាច់ប្រាក់គ្រប់ចំនួនទៅឲ្យ Y ។ ប៉ុន្តែ Y បាននិយាយមកកាន់ខ្ញុំថា "វាជាប្រាក់ដែលគ្មានភាពចាំបាច់ត្រូវសង" ជាដើម ហើយមិនសងប្រាក់នោះឲ្យមកខ្ញុំទេ។ លើសពីនេះទៀត ខ្ញុំគិតថា គួរឲ្យអាណិត បើឲ្យ Y សងទាំងការប្រាក់ទៀត ហេតុនេះ ខ្ញុំទាមទារឲ្យបង់តែប្រាក់កម្ចីដែលជាប្រាក់ដើមចំនួន 10ម៉ឺនដុល្លារប៉ុណ្ណោះ ។



ការអះអាងរបស់X

# ការទាមទារឲ្យសងប្រាក់កម្ចី

- គោលបំណងនៃការទាមទារ
  បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន 10ម៉ឺនដុល្លារមកឲ្យដើមចោទ។

- កម្មវត្ថុនៃបណ្ដឹង
  សិទ្ធិទាមទារឲ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ

- ចំនួនកម្មវត្ថុនៃបណ្ដឹង
  ＝ចំនួនកិច្ចសន្យា 1

※អំពីសិទ្ធិលើបំណុលចំពោះការប្រាក់ ដោយសារតែដើមចោទមិនទាមទារ ដូច្នេះ មិនក្លាយជាកម្មវត្ថុនៃបណ្ដឹងទេ។

# ការទាមទារឲ្យសងប្រាក់កម្ចី

- តើអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់ជាអ្វី?

មាត្រា578

ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឲ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ឬ វត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឲ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុដែលទទួលពីអ្នកឲ្យខ្ចីនោះ។

មាត្រា579

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឲ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ។

⇒ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគ ចាំបាច់ត្រូវមានការព្រមព្រៀងអំពីការសងកម្មវត្ថុនៃកិច្ចសន្យា។

# ការទាមទារឲ្យសងប្រាក់កម្ចី

- តើអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់កម្ចីជាអ្វី?

  ប្រសិនបើ កិច្ចសន្យាខ្ចីប្រាក់បានបង្កើតឡើង តើសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីនឹងកើតឡើងភ្លាមដែរឬទេ ?

⇒NO

មូលហេតុ(1)：ការប្រគល់កម្មវត្ថុ

មូលហេតុ(2)：ការបញ្ចប់កិច្ចសន្យាខ្ចីបរិភោគ (ការមកដល់របស់កាលបរិច្ឆេទនៃការសង)

# ការទាមទារឲ្យសងប្រាក់កម្ចី

- តើអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់កម្ចីជាអ្វី?

(1) អំពីការប្រគល់កម្មវត្ថុ

កិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ (ក្រមរដ្ឋប្បវេណីមាត្រា579) ប៉ុន្តែ គេគិតថា ដើម្បីទាមទារឲ្យ Y សងកម្មវត្ថុនៃកិច្ចសន្យានោះវិញ X ត្រូវប្រគល់កម្មវត្ថុនោះឲ្យទៅ Y និង បានប្រគល់ការប្រើប្រាស់ដោយសេរីទៅ Y ដោយផ្អែកតាមកិច្ចសន្យាជាមុនសិន។

⇒ការប្រគល់កម្មវត្ថុនៃកិច្ចសន្យា គឺជាការចាំបាច់ដើម្បីឲ្យសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីកើតឡើង ។

# ការទាមទារឲ្យសងប្រាក់កម្ចី

- តើអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់កម្ចីជាអ្វី?

(2) អំពីការបញ្ចប់កិច្ចសន្យាខ្ចីបរិភោគ (ការមកដល់របស់កាលបរិច្ឆេទនៃការសង)

កិច្ចសន្យាខ្ចីបរិភោគដែលមិនបានកំណត់អំពីកាលបរិច្ឆេទនៃការសងក៏ដោយ ក៏មានសុពលភាពដែរ (ក្រមរដ្ឋប្បវេណីមាត្រា594 កថា.ទី2 ជាអាទិ៍) ហេតុនេះ ការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសងមិនមែនជាលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគទេ។

ប៉ុន្តែ ដោយសារតែកិច្ចសន្យាខ្ចីបរិភោគ ជាកិច្ចសន្យាដែលអ្នកឲ្យខ្ចីត្រូវប្រគល់ការប្រើប្រាស់ដោយសេរីនូវវត្ថុដែលជាកម្មវត្ថុឲ្យទៅអ្នកខ្ចីក្នុង "អំឡុងពេលដែលមានកំណត់" (ក្រមរដ្ឋប្បវេណីមាត្រា578) ហេតុនេះ បើសិនជា "អំឡុងពេលដែលមានកំណត់" ពោលគឺ អំឡុងពេលនៃកិច្ចសន្យាខ្ចីបរិភោគមិនទាន់បានបញ្ចប់នៅឡើយ នោះអ្នកឲ្យខ្ចីមិនអាចទាមទារឲ្យសងកម្មវត្ថុបានឡើយ ។

# ការទាមទារឲ្យសងប្រាក់កម្ចី

- តើអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់កម្ចីជាអ្វី?

(2) អំពីការបញ្ចប់កិច្ចសន្យាខ្ចីបរិភោគ (ការមកដល់របស់កាលបរិច្ឆេទនៃការសង)

លើសពីនេះ ក្រមរដ្ឋប្បវេណីមាត្រា591 កថាខណ្ឌទី១ បញ្ញត្តថា «អ្នកខ្ចី មានករណីយកិច្ចត្រូវសងទៅឲ្យអ្នកឲ្យខ្ចី នូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលការប្រគល់ នៅថ្ងៃដែលត្រូវសង។ » ហេតុនេះ យើងអាចគិតបានថា ការមកដល់នូវ «ថ្ងៃដែលត្រូវសង» គឺជាលក្ខខណ្ឌនៃការទាមទារឲ្យសង។

⇒<u>ការបញ្ចប់កិច្ចសន្យា គឺជាការចាំបាច់ដើម្បីឲ្យសិទ្ធិទាមទារឲ្យសងប្រាក់កម្ចីកើតឡើង </u>។

# ការទាមទារឲ្យសងប្រាក់កម្ចី

- តើអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់កម្ចីជាអ្វី?

វិធីនៃការអះអាងលម្អិតអំពីការបញ្ចប់កិច្ចសន្យាខ្ចីបរិភោគ

①ករណីមានការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសង

ការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសង និង ការមកដល់នៃកាលបរិច្ឆេទនោះ

②ករណីគ្មានការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសង

ការដាស់តឿនឲ្យសង និង ការកន្លងផុតនៃអំឡុងពេលសមរម្យ (ក្រមរដ្ឋប្បវេណី មាត្រា594 កថា.ទី2)

※ផ្អែកតាមមាត្រានេះចែងថា "អ្នកឲ្យខ្ចីអាចដាស់តឿនឲ្យសងដោយកំណត់អំឡុងពេលសមរម្យបាន" ប៉ុន្តែ ទោះបីជានៅពេលដាស់តឿន អ្នកឲ្យខ្ចីមិនបានកំណត់អំឡុងពេលសមរម្យក៏ដោយ បើសិនជាអំឡុងពេលសមរម្យគិតចាប់ពីពេលដែលបានដាស់តឿនបានកន្លងផុត នោះវានឹងក្លាយទៅជាការមកដល់នៃកាលបរិច្ឆេទនៃការសង។

# ការទាមទារឲ្យសងប្រាក់កម្ចី

- សរុបអំពីអង្គហេតុចម្បងនៃការទាមទារឲ្យសងប្រាក់កម្ចី

① ការព្រមព្រៀងអំពីការសងកម្មវត្ថុ

② ប្រគល់កម្មវត្ថុផ្អែកតាម ①

③ ការបញ្ចប់កិច្ចសន្យាខ្ចីបរិភោគ

③—1 (ករណីមានការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសង)

ការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសង និង ការមកដល់នៃកាលបរិច្ឆេទនោះ

③—2 (ករណីគ្មានការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសង)

ការដាស់តឿនឲ្យសង និង ការកន្លងផុតនៃអំឡុងពេលសមរម្យ

# ការទាមទារឲ្យសងប្រាក់កម្ចី

- អង្គហេតុចម្បងនៃករណីសិក្សានេះ

1. ថ្ងៃទី8 ខែសីហា ឆ្នាំ2016 X និង Y បានព្រមព្រៀងគ្នា ដោយ X ឲ្យ Y ខ្ចីប្រាក់ចំនួន 10ម៉ឺនដុល្លារ។

2. ថ្ងៃដដែល X បានប្រគល់ប្រាក់ចំនួន 10ម៉ឺនដុល្លារឲ្យទៅ Y ផ្អែកលើកិច្ចសន្យាខាងលើ។

3. ពេលចុះកិច្ចសន្យាខាងលើ X និង Y បានកំណត់យកថ្ងៃទី1 ខែធ្នូ ឆ្នាំ2016 ជាកាលបរិច្ឆេទនៃការសង។

4. ថ្ងៃទី1 ខែធ្នូ ឆ្នាំ2016 បានមកដល់។

# ការទាមទារឲ្យសងប្រាក់កម្ចី



ការអះអាងរបស់Y

ជាការពិត ខ្ញុំបានទទួលសាច់ប្រាក់ចំនួន 10ម៉ឺនដុល្លារពី X ដែលជាឪពុកក្មេក របស់ខ្ញុំ (ឪពុករបស់ប្តីខ្ញុំឈ្មោះថា A) ប៉ុន្តែ វាជាប្រាក់ដែល X បានធ្វើប្រទានកម្មមកឲ្យខ្ញុំ ដើម្បីយកធ្វើជាទុនក្នុងការឈរឈ្មោះបោះឆ្នោត។ ការលើកឡើងថា ប្រាក់នោះជាទុនសម្រាប់បើកក្រុមហ៊ុន គឺខុសហើយ។ តាំងពីដើម X ក៏បានដឹងរឿងនេះដែរ ហើយដោយសារតែប្រាក់នេះកំពុងតែប្រើប្រាស់ជាទុនសម្រាប់ការបោះឆ្នោត ដូច្នេះ វាមិនមែនជាប្រាក់ដែលមានគោលបំណងត្រូវសងតាំងពីដំបូងមកម្ល៉េះ។ ហេតុនេះ ប្រាក់នេះ ជាប្រាក់ដែលគ្មានភាពចាំបាច់ត្រូវសងឡើយ។ មូលហេតុដែល X និយាយថាឲ្យខ្ញុំត្រូវតែសងបែបនេះ នៅក្នុងពេលនេះ ក៏ព្រោះតែជីវិតអាពាហ៍ពិពាហ៍ខ្ញុំ និង A កំពុងតែបែកបាក់ ហើយនឹងត្រូវលែងលះគ្នាក្នុងពេលឆាប់ៗនេះ។

# ការទាមទារឲ្យសងប្រាក់កម្ចី

• តើការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ នឹងក្លាយជាយ៉ាងណា?

1. ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៦ X និង Yបានព្រមព្រៀងគ្នា ដោយ X ឲ្យ Y ខ្ចីប្រាក់ចំនួន១០ម៉ឺនដុល្លារ។

⇒Y អះអាងថា X បានធ្វើប្រទានកម្មនូវប្រាក់ចំនួន១០ម៉ឺនដុល្លារមកឲ្យខ្លួន។

ដោយសារតែការអះអាងនេះ មិនស្របគ្នានឹងកិច្ចសន្យាខ្ចីបរិភោគនូវប្រាក់ចំនួន១០ម៉ឺនដុល្លារទេ ហេតុនេះ វានឹងក្លាយទៅជាការមិនទទួលស្គាល់ចំពោះការបង្កើតកិច្ចសន្យាខ្ចីបរិភោគ (ការព្រមព្រៀងអំពីការសងកម្មវត្ថុ)។

※ Y មិនចាំបាច់ខិតខំបញ្ជាក់ចំពោះការអះអាងអំពីអត្ថិភាពនៃកិច្ចសន្យាប្រទានកម្មនូវប្រាក់ចំនួន១០ម៉ឺនដុល្លារនោះទេ Y គ្រាន់តែលើកឡើងអំពីភាពមិនច្បាស់លាស់ ថាជាការពិត ឬ មិនមែនដែលមានចំពោះអត្ថិភាពនៃការព្រមព្រៀងអំពីការសងប្រាក់ចំនួន១០ម៉ឺនដុល្លារ គឺគ្រប់គ្រាន់។

# ការទាមទារឲ្យសងប្រាក់កម្ចី

• តើការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ នឹងក្លាយជាយ៉ាងណា?

2. ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៦ X បានប្រគល់ប្រាក់ចំនួន១០ម៉ឺនដុល្លារ ឲ្យទៅ Y ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ។

⇒ការអះអាងនេះចេញពីអង្គហេតុចំនួន២ ①ការប្រគល់ប្រាក់ចំនួន១០ម៉ឺនដុល្លារ ②ការប្រគល់វត្ថុនោះផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ។

Y ទទួលស្គាល់ចំពោះការទទួលប្រាក់ចំនួន១០ម៉ឺនដុល្លារពី X ប៉ុន្តែ អះអាងថា ការទទួលស្គាល់នោះ ធ្វើឡើងដោយផ្អែកលើកិច្ចសន្យាប្រទានកម្ម មិនមែនកិច្ចសន្យាខ្ចីបរិភោគទេ។

ហេតុនេះ Y ទទួលស្គាល់ចំណុច①ខាងលើ (សារភាព) និងបដិសេធចំណុច②។

# ការទាមទារឲ្យសងប្រាក់កម្ចី

• តើការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ នឹងក្លាយជាយ៉ាងណា?

3. នៅពេលចុះកិច្ចសន្យាខ្ចីបរិភោគ X និង Y បានកំណត់យកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦ ជាកាលបរិច្ឆេទនៃការសង។

⇒ដោយសារតែ Y មិនទទួលស្គាល់អំពីអត្ថិភាពនៃកិច្ចសន្យាខ្ចីបរិភោគ ហេតុនេះ គេគិតថា Y ក៏មិនទទួលស្គាល់ចំពោះការព្រមព្រៀងអំពីការបរិច្ឆេទសងផងដែរ។

4. ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦ បានមកដល់។

⇒ដោយសារតែអង្គហេតុនេះ មានភាពជាក់ស្តែង ហេតុនេះ ពុំចាំបាច់ទទួលស្គាល់ទេ។

# ការទាមទារឲ្យសងប្រាក់កម្ចី

- ការអះអាងអំពីការតវ៉ា
  ក្នុងករណីសិក្សានេះ Y មិនបានអះអាងអំពីអង្គហេតុដែលត្រូវនឹងការតវ៉ានោះទេ។

- អង្គហេតុក្រៅពីនោះ
  កម្មវត្ថុនៃការប្រគល់ប្រាក់  ទំនាក់ទំនងផ្ទាល់ខ្លួនរវាង Y និង A ជាដើម...

⇒អង្គហេតុនេះ  មិនមែនជាអង្គហេតុចម្បងទេ  ប៉ុន្តែ  វាជាក៏ជាអង្គហេតុដែលមានសារៈសំខាន់ផងដែរ ដើម្បីឲ្យតុលាការសន្មតអំពីអត្ថិភាពនៃអង្គហេតុចម្បង ឬ ជាអង្គហេតុប្រយោលដែលឲ្យតុលាការគេចចេញពីការសន្មត  នៅពេលធ្វើការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុចម្បង។

# ការទាមទារឲ្យសងប្រាក់កម្ចី

- សរុបករណីសិក្សានេះ

1. ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៦ X និង Y បានព្រមព្រៀងគ្នាថា Xឲ្យ Y ខ្ចីប្រាក់ចំនួន១0ម៉ឺនដុល្លារ។
   →មិនទទួលស្គាល់
2. ថ្ងៃដដែល X បានប្រគល់ប្រាក់ឲ្យទៅ Y ចំនួន១0ម៉ឺនដុល្លារ ដោយផ្អែកតាមកិច្ចសន្យាខាងលើ។
   →ទទួលស្គាល់ចំពោះការប្រគល់ប្រាក់ចំនួន១0ម៉ឺនដុល្លារ  ហើយក្រៅពីនោះមិនទទួលស្គាល់។
3. នៅពេលចុះកិច្ចសន្យា X និង Y បានកំណត់យកថ្ងៃទី១ ខែ១២ ឆ្នាំ២០១៦ ជាកាលបរិច្ឆេទនៃការសង។
   →មិនទទួលស្គាល់
4. ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៦ បានមកដល់។
   →មានភាពជាក់ស្តែង

# ការទាមទារឲ្យសងប្រាក់កម្ចី

ចំណុចសំខាន់នៃការទាមទារឲ្យសងប្រាក់

- ចំពោះការទាមទារឲ្យបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ប្រសិនបើគូភាគីបានបង្កើតកិច្ចសន្យាលក់ទិញ អ្នកលក់នឹងអាចបង្គាប់ឲ្យអ្នកទិញបង់ប្រាក់បានភ្លាម ហេតុនេះការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសងនឹងក្លាយទៅជាការតវ៉ា។

- ប៉ុន្តែ ចំពោះការទាមទារឲ្យសងប្រាក់កម្ចីដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគវិញ សិទ្ធិទាមទារឲ្យសងប្រាក់កម្ចីនឹងកើតមានឡើងនៅពេលបញ្ចប់កិច្ចសន្យាខ្ចីបរិភោគ ហេតុនេះការព្រមព្រៀងអំពីកាលបរិច្ឆេទនៃការសងនឹងក្លាយទៅជាមូលហេតុនៃការទាមទារ។

# ចប់

# ការបង្រៀនអំពីអត្ថហេតុចម្បង លើកទី៥

ជំនាញការនៃគម្រោងជំនួយច្បាប់
ម៉ាអិដា យូតា

# ការទាមទារឲ្យសងប្រាក់កម្ចី



នៅថ្ងៃទី15 ខែមិថុនា ឆ្នាំ2017 ខ្ញុំបានព្រមព្រៀងឲ្យ Y ខ្ចីប្រាក់ចំនួន 1ម៉ឺនដុល្លារ ហើយនៅថ្ងៃនោះ ខ្ញុំបានប្រគល់ប្រាក់សុទ្ធចំនួន 1ម៉ឺន ដុល្លារឲ្យ Y ដោយសន្យានឹងគ្នាថា ថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017 គឺជាកាលបរិច្ឆេទនៃការសង ដូច្នេះ ខ្ញុំទាមទារឲ្យ Y សងប្រាក់ចំនួន 1 ម៉ឺនដុល្លារដែលជាប្រាក់ដើមនៃប្រាក់កម្ចី។

ការអះអាងរបស់ X

# ការទាមទារឲ្យសងប្រាក់កម្ចី

- គោលបំណងនៃការទាមទារ

  បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ‌1ម៉ឺនដុល្លារ ឲ្យទៅដើមចោទ។

- កម្មវត្ថុនៃបណ្តឹង

  សិទ្ធិទាមទារឲ្យសងប្រាក់កម្ចីផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ចំនួន1

# ការទាមទារឲ្យសងប្រាក់កម្ចី

• មូលហេតុនៃការទាមទារ

1. នៅថ្ងៃទី15 ខែមិថុនា ឆ្នាំ2017 X និង Y បានព្រមព្រៀងគ្នាថា X ឲ្យ Y ខ្ចីប្រាក់ចំនួន 1ម៉ឺនដុល្លារ។

2. X បានប្រគល់ប្រាក់ចំនួន 1ម៉ឺនដុល្លារ ឲ្យទៅ Y នៅថ្ងៃដដែលដោយផ្អែកលើកិច្ចសន្យាខាងលើ។

3. នៅពេលធ្វើកិច្ចសន្យាខាងលើ X និង Y បានកំណត់ថា យកថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017 ជាកាលបរិច្ឆេទនៃការសង។

4. ថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017 បានមកដល់។

# ការទាមទារឲ្យសងប្រាក់កម្ចី

ខ្ញុំមិនច្រឡំទេដែលថាបានខ្ចីប្រាក់ចំនួន 1ម៉ឺនដុល្លារ ពី X នោះ ប៉ុន្តែ នៅថ្ងៃទី1 ខែមិថុនា ឆ្នាំ2017 ខ្ញុំបាន សងគ្រប់ចំនួនរួចហើយ។



ការអះអាងរបស់ Y

# ការទាមទារឲ្យសងប្រាក់កម្ចី

- ការទទួលស្គាល់ ឬ បដិសេធចំពោះការទាមទារ ទទួលស្គាល់ទាំងអស់។

# ការតវ៉ាចំពោះការសង

ក្រមរដ្ឋប្បវេណី មាត្រា433

កាតព្វកិច្ចត្រូវរលត់ដោយហេតុដូចខាងក្រោមនេះ ៖

ក.ការសង ការទូទាត់ ការលើកលែង នវកម្ម ឬ ព្យាកុលភាព ដូចបានកំណត់ពីផ្នែកទី១ (ការសង) ដល់ផ្នែកទី៥ (ព្យាកុលភាព) នៃជំពូកទី៧ នេះ។

【សង្ខេបចាប់ពីចំណុច ខ.】

⇒ ការសងនឹងក្លាយទៅជាការតវ៉ាដែលជាមូលហេតុនៃការរលត់សិទ្ធិទាមទារឲ្យសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។

# ការតវ៉ាចំពោះការសង

- អង្គហេតុចម្បងនៃការសង

① កូនបំណុល (ឬ តតិយជន) បានផ្តល់តាវលិកចំពោះម្ចាស់បំណុល

② ការផ្តល់តាវកាលិក①ត្រូវបានធ្វើឡើងជាការអនុវត្តកាតព្វកិច្ចនោះ

⇒ក្នុងករណីសិក្សានេះ

① Y បានបង់ប្រាក់ចំនួន 1ម៉ឺនដុល្លារ ឲ្យទៅ X នៅថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017។

② ការបង់ប្រាក់① ត្រូវបានធ្វើឡើងជាការអនុវត្តកាតព្វកិច្ចសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគនៃរឿងក្តីនេះ ។

# សរុប

- មូលហេតុនៃការទាមទារ

  1. នៅថ្ងៃទី15 ខែមិថុនា ឆ្នាំ2017 X និង Y បានព្រមព្រៀងគ្នាថា X ឲ្យY ខ្ចីប្រាក់ចំនួន1ម៉ឺនដុល្លារ។

  2. X បានប្រគល់ប្រាក់ចំនួន1ម៉ឺនដុល្លារ ឲ្យទៅ Y នៅថ្ងៃដដែលដោយផ្អែកលើកិច្ចសន្យាខាងលើ។

  3. នៅពេលធ្វើកិច្ចសន្យាខាងលើ X និង Y បានកំណត់ថា យកថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017 ជាកាលបរិច្ឆេទនៃការសង។

  4. ថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017 បានមកដល់។

- ការទទួលស្គាល់ ឬ បដិសេធចំពោះមូលហេតុនៃការទាមទារ

  ទទួលស្គាល់មូលហេតុនៃការទាមទារ 1～3។ (4 គឺជាអង្គហេតុដែលមានភាពជាក់ស្តែង)

# សរុប

- ការតវ៉ា (ការសង)

នៅថ្ងៃទី1 ខែកញ្ញា ឆ្នាំ2017 Y បានបង់ប្រាក់ចំនួន 1ម៉ឺនដុល្លារឲ្យទៅ X ដែលជាការអនុវត្តកាតព្វកិច្ចសងប្រាក់កម្ចីដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។

- ការទទួលស្គាល់ ឬ បដិសេធចំពោះការសង

បដិសេធការសង។

# ចប់